សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៧ មិនា ២០១៤

- **សូមគោរព លោកស្រី អាកេមិ តាកាហាហ្ស៊ិ** (TAKAHASHI Akemi) **នាយិកា មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ** (FIDR)!
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយណាស់ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុននៅថ្ងៃនេះសម្រាប់គម្រោងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងខេត្តកំពង់ឆ្នាំង។

សម្រាប់គម្រោងលើកនេះ FIDRនឹងប្រើប្រាស់ជំនួយឧបត្ថម្ភសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដើម្បីកែលម្អជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តកំពង់ឆ្នាំង តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងកសិកម្មខ្នាតតូចជាលក្ខណៈគ្រួសារ ការកែលម្អស្ថានភាពសុខភាព ការបង្កើនផលិតកម្មស្រូវ និងបង្កើនចំណេះដឹងផ្នែកថែរក្សាអនាម័យ ព្រមទាំងការសាងសង់បណ្តាញគមនាគមន៍ជាដើម។ ជាងនេះទៅទៀត មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំងរួមនឹងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបរិបូរណ៍ក៏នឹងសហការជាមួយFIDRដែលយើងសង្ឃឹមថាកិច្ចសហប្រតិបត្តិការរវាងប្រជាជននិងអាជ្ញាធរនឹងជំរុញឲ្យគម្រោងក្នុងតំបន់គោលដៅនេះទទួលបានជោគជ័យ។

ការពង្រឹងវិស័យកសិកម្ម គឺជាគោលដៅមួយដ៏សំខាន់សម្រាប់អនាគតរបស់ប្រទេសកម្ពុជាដែលជាប្រទេសកសិកម្មមួយ ហេតុដូចនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យនេះជាមុំមួយក្នុងបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណដើម្បីអភិវឌ្ឍន៍ជាតិ។ ដោយអនុលោមតាមគោលការណ៍នេះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់វិស័យកសិកម្មនៅប្រទេសកម្ពុជាតាមរយៈការផ្តល់ជាជំនួយបច្ចេកទេសនានា។ យ៉ាងណាមិញ សម្រាប់គម្រោងផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលរួមបញ្ចូលគ្នាបែបនេះនៅមិនទាន់មាននៅឡើយ មិនតែប៉ុណ្ណោះ ផ្នែកទាំងពីរនេះនៅមិនទាន់ឆ្លើយតបនឹងតម្រូវការដែលយើងសង្ឃឹមថាគម្រោងនេះនឹងជួយគាំទ្របន្ថែមដល់បញ្ហានេះ។

FIDR បានចាប់ផ្តើមសកម្មភាពលើកស្ទួយវិស័យកសិកម្មរបស់ខ្លួននៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងតាំងពីឆ្នាំ២០០៧មកម្លេះ។ ហើយបន្ទាប់ពីចុះអនុស្សារណៈព្រមព្រៀងគ្នាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ២០១១រួចមក អង្គការនេះក៏បានពង្រីកតំបន់គោលដៅរបស់ខ្លួនទៅកាន់ភូមិថ្មីចំនួន៣៩នៃឃុំ៥ ក្នុងស្រុកចំនួន២។ យើងសង្ឃឹមយ៉ាងមុតមាំថាគម្រោងលើកនេះនឹងរួមចំណែកយ៉ាងធំធេងក្នុងការកាត់បន្ថយភាពក្រីក្រក្នុងខេត្តកំពង់ឆ្នាំង។

ខ្ញុំបានទទួលដំណឹងថាខេត្តកំពង់ឆ្នាំងដែលជាតំបន់គោលដៅលើកនេះ គឺជាខេត្តមួយដែលមានអត្រាប្រជាជនក្រីក្រច្រើនជាងគេលំដាប់ទីពីរក្នុងចំណោម២៤ខេត្ត-រាជធានី ជាពិសេសក្នុងស្រុករលាប្អៀ និងស្រុកបរិបូរណ៍មានប្រជាជនជិតពាក់កណ្ដាលកំពុងរស់ក្នុងសភាពក្រីក្រ និងខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ដោយមានកិច្ចសហការរវាងវិស័យកសិកម្ម និងសុខាភិបាល គម្រោងនេះមានទិសដៅកាត់បន្ថយភាពក្រីក្រ និងកែលម្អស្ថានភាពអាហារូបត្ថម្ភ ព្រមទាំងពង្រឹងសមត្ថភាពបង្កើនចំណូលដោយខ្លួនឯងសម្រាប់ប្រជាជនក្នុងតំបន់គោលដៅ ហើយយើងសង្ឃឹមថា គម្រោងនេះនឹងក្លាយជាគម្រោងគំរូមួយសម្រាប់កំណែទម្រង់ថ្មីនៃវិស័យកសិកម្មសម្រាប់ប្រទេសកម្ពុជា។

ជាចុងក្រោយ ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្ដល់ជូនអង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្ដល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!